សារព័ត៌មាន
# ខ្មែរម្ចាស់ស្រុក
Khmer Machas Srok News

សារព័ត៌មានចេញផ្សាយប្រចាំថ្ងៃ
ឆ្នាំទី ០២ លេខ ២៤៦ ចេញផ្សាយថ្ងៃ ព្រហស្បតិ៍ ទី ១៨ ខែ កញ្ញា ឆ្នាំ ២០០៨

## លោក យ៉ាស្ហ ហ្គាយ ប្រកាសលាលែងពីតំណែង ប្រេសិតពិសេស អ.ស.ប ទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា


លោក យ៉ាស្ហ ហ្គាយ លាលែងពីតំណែងទាំងក្តីឈឺចាប់


លោក ខៀវ កាញារីទ្ធ

ដោយ : វិសាល

លោក *យ៉ាស្ហ ហ្គាយ* ប្រេសិតពិសេសរបស់អគ្គលេខាធិការ អង្គការសហប្រជាជាតិ ( អ.ស.ប ) ទទួលបន្ទុកផ្នែកសិទ្ធិមនុស្ស នៅកម្ពុជាដែលមជ្ឈដ្ឋាននានា ស្គាល់យ៉ាងច្បាស់ថា លោកជាមនុស្សម្នាក់ដែលហ៊ានរិះគន់

តទៅទំព័រ២ ស

## តំរោងយាងត្រឡប់ របស់សម្តេចក្រុមព្រះ អាចប្រែប្រួលបើមិនប្រគល់ដីឱ្យហ៊្វុនស៊ិនប៉ិចវិញទេ


ទ្រង់ រណឫទ្ធិ ដ៏មហាយ៉ាប់


លោក ញឹក ប៊ុនឆៃ អគ្គលេខាធិការគណបក្សហ៊្វុនស៊ិនប៉ិច

ដោយ : រតនៈ

ទ្រង់*នរោត្តម រណឫទ្ធិ* ប្រធានគណបក្សនរោត្តមរណឫទ្ធិ ដែលគ្រោងយាងត្រឡប់ មកប្រទេសកម្ពុជាវិញ នៅក្រោយការបង្កើតរដ្ឋាភិបាលកញ្ចប់អាណត្តិទី៤នោះអាចនឹងប្រែប្រួលវិញ បើសិនជាព្រះអង្គមិនព្រម

តទៅទំព័រ២ ច

## ការផ្លាស់ប្តូរតំណែងអភិបាលក្រុងព្រះសីហនុ ពាក់ព័ន្ធនឹងនាយឧត្តមសេនីយផ្កាយមាស៤ម្នាក់

ដោយ: ស្សាវរីយ៍

កាលពីថ្ងៃទី៤កញ្ញា២០០៨ មានពិធី ផ្លាស់ប្តូរតំណែង អភិបាលក្រុងព្រះសីហនុ លោក*សាយ ហាក់*កូតាគណបក្សហ៊្វុនស៊ិនប៉ិច ដាក់ជំនួសវិញដោយលោក*ស្បោង សារ៉ាត* មកពីគណបក្សប្រជាជន ។ ប៉ុន្តែការ

តទៅទំព័រ២ គ


លោក ស្បោង សារ៉ាត


លោក សាយ ហាក់

## សម រង្ស៊ី ស្នើឱ្យ ហ៊ុន សែន បញ្ជាក់អំពីមូលហេតុមិនសុំការឧបត្ថម្ភពីសហប្រធានសន្និសីទទីក្រុងប៉ារីសក្នុងរឿងសៀមឈ្លានពានខ្មែរ


លោក សម រង្ស៊ី មេដឹកនាំគណបក្សជំទាស់នៃប្រទេសកម្ពុជា


លោក ហ៊ុន សែន នាយករដ្ឋមន្ត្រីល្ងោតនឹងអំណាចមិនស្កប់ស្កល់

ដោយ : សច្ចៈ

លោក*សម រង្ស៊ី*អ្នកតំណាងរាស្ត្រមណ្ឌលកំពង់ចាម និងជាប្រធានគណបក្សសមរង្ស៊ីបាន ធ្វើជាលិខិតមួយច្បាប់ស្នើទៅនាយករដ្ឋមន្ត្រី*ហ៊ុនសែន* ដោយ សុំឱ្យបុរសខ្លាំងម្នាក់នេះបញ្ជាក់អំពីមូលហេតុដែលខ្លួនមិនពិនិត្យលទ្ធភាពក្នុងការសុំការឧបត្ថម្ភ ពីសហប្រធានសន្និសីទក្រុងប៉ារីសស្តីពីកម្ពុជាក្នុងរឿងទាហាន

តទៅទំព័រ៤ ន

## ល្បិចសៀមបោករដ្ឋាភិបាលខ្មែរនិងបំភ័ន្តភ្នែក ពិភពលោកលេចចេញក្រឡាកាន់តែច្បាស់ហើយ


ប្រាសាទព្រះវិហារដែលជាកេរមរតកដ៏មានតម្លៃរបស់ជាតិខ្មែរ


ប្រាសាទតាមាន់ធំស្ថិតនៅក្នុងមហិច្ឆតារបស់ទាហានសៀមឈ្លានពាន


លោក ហោ ណាំហុង


លោក ទៀ បាញ់


ទាហានខ្មែរ និងទាហានសៀមពេលប្រឈមមុខដាក់គ្នានៅតំបន់ប្រាសាទព្រះវិហារ

ដោយ : គ.អរពិន្ទ

ទាល់តែមកដល់រសៀលថ្ងៃអង្គារទី១៦ខែកញ្ញាឆ្នាំ២០០៨ ពេលដែលមន្ត្រីជាន់ខ្ពស់ម្នាក់ នៃរដ្ឋមន្ត្រីការបរទេសប្រទេសសៀមប្រកាសចោទប្រកាន់ថា ទាហានខ្មែរចូលរំលោភឈ្លានពានទឹកដីសៀមនោះ ទើបគេមើលឃើញ និងដឹងយ៉ាងច្បាស់ថា សៀមបានបោកប្រាស់រដ្ឋាភិបាលកម្ពុជា និងធ្វើអ្វីៗដើម្បីបំភ័ន្ត

តទៅទំព័រ៤ ម

## នាយករដ្ឋមន្ត្រីខ្មាស់សំដី សុន ឆ័យ ទើបឱ្យ គាត ឈន់ រកវិធីបញ្ចុះតម្លៃប្រេងឥន្ធនៈ


លោក សុន ឆ័យ អ្នកតំណាងរាស្ត្រគណបក្សសមរង្ស៊ីមណ្ឌលភ្នំពេញ


លោក គាត ឈន់ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដ៏អសមត្ថភាព

ដោយ : ជ.ឧត្តម

មេដឹកនាំដុះស្លែនៃប្រទេសកម្ពុជាបានសន្យាស្ទើរសឹកអណ្តាត អស់ទៅហើយថា នឹងព្យាយាមឱ្យអស់ពីលទ្ធភាពក្នុងការទប់ទល់ចំពោះតម្លៃប្រេងឥន្ធនៈ ដែលឡើងថ្លៃខ្ពស់កប់ពពកនាពេលកន្លងមក។ ហើយឥឡូវនេះទៀតសោត មេដឹកនាំដុះស្លែដដែលនេះបានសន្យាទាំងមុខក្រាស់ទៀតថា គាត់នឹងឱ្យ

តទៅទំព័រ៣ ខ

ប្រសិនបើលោកអ្នកមានចំណាប់អារម្មណ៍
ផ្សព្វផ្សាយ ពាណិជ្ជកម្ម
លើទំព័រសារព័ត៌មាន ខ្មែរម្ចាស់ស្រុក
សូមទាក់ទងមកកាន់
ទូរស័ព្ទ : 012 850 690, 015 645 170
ទូរសារ : 023 987 411
E-mail : kmsnews@gmail.com
http://kmsblog.wordpress.com

ដំណឹងពិសេសដ៏អស្ចារ្យ

ពីលោកគ្រូ **ហោ លីម** ព្យាបាលតាមរបៀបម៉ាស្សា លាប រឹត ស្ទំ ថ្នាំបុរាណខ្មែរ ធូរស្បើយក្នុង រយៈពេល **១ម៉ោង ( មិនធូរស្បើយមិនគិតលុយ)** នូវជំងឺមនុស្សចាស់ ចុកចាប់ក្នុងរាងកាយ, ឈឺក្បាលជាយូរឆ្នាំក្តី, ឈឺជង្គង់, ឈឺសន្លាក់ដៃ សន្លាក់ជើង, រោយឆ្អឹងខ្នង, តឹងច្រមុះ, តឹងទ្រូង, ថប់ដង្ហើម, ញ័រទ្រូង, ទល់ឆ្អល់ក្នុងពោះ, ពិបាកបត់ជើងតូចធំ, ជាពិសេសជំងឺ១០០មុខក្នុង រាងកាយ ។ល។ **ផ្នែកសម្រស់ :** សង្វាពោះក្រាស់ ជាំមុខ គ្មានដោះ ឬដោះស្បែត ព្យាបាល យ៉ាងស័ក្តិសិទ្ធ។

- មានបន្ទប់បុរស ស្ត្រី ដាច់ដោយឡែកពីគ្នា
- មានលក់ថ្នាំសម្រាប់ព្យាបាលដោយខ្លួនឯង

ទីតាំងផ្ទះលេខ០៧៧ **ហោ លីម ថែសម្ផស្ស** ច្រកចូលផ្លូវមានដំបូល ជាប់របងស្អាតចាស់ សង្កាត់ស្រះចក ខណ្ឌដូនពេញ

ទូរស័ព្ទទំនាក់ទំនង : 012 363 331, 016 719 616,

*បរិយាយថ្ងៃនេះ*

## ហ៊ុន សែន ដេកភ័យលាយអរថាមួយអាទិត្យទៀត ខ្លួននឹងក្លាយជានាយករដ្ឋមន្ត្រីថ្មី

ដោយ : ហង្ស ច្រាផ្កា

បញ្ហានៃការរំលោភបំពានរបស់ប្រទេសជិតខាង មិនមែនតែសៀមដែលកំពុងគឃ្លើននោះទេ ប៉ុន្តែក៏ពីសំណាក់យួន និងលាវផងដែរ ទាំងហ្នឹងបញ្ជាក់ឱ្យដឹងថា គឺជាការដឹកនាំដ៏អន់ខ្សោយរបស់រដ្ឋាភិបាលគណបក្សប្រជាជន ហ៊ុន សែន ដែលតែងតែរណបខ្លបខ្លាចប្រទេសជិតខាង ប៉ុន្តែបែរជាធ្វើខ្លាំងអាងកម្លាំងបាយតែខាងបង្ក្រាបខ្មែរគ្នាឯងនោះ។

តទៅទំព័រ៤ ក

**តមកពីទំព័រ១ គ**

ផ្លាស់ប្តូរនេះ ត្រូវបានគេដឹងថា មិនមែនបណ្តាលមកពីកូតានៃគណបក្សទេគឺផ្តើមចេញពីករណីទំនាស់ដីធ្លីរវាងសាច់ញាតិរបស់នាយឧត្តមសេនីយ៍ ផ្កាយមាស៤ម្នាក់ នៅក្រសួងការពារជាតិ ជាមួយនឹងអាជ្ញាធរ ក្រុងព្រះសីហនុ ។

មន្ត្រីសាលាក្រុងព្រះសីហនុម្នាក់បានអោយដឹងថា នៅក្នុងរយៈពេល៤ឆ្នាំនៃការធ្វើជាអភិបាលក្រុងព្រះសីហនុ នៃរដ្ឋាភិបាលអាណត្តិទី៣កន្លងទៅនេះ អាជ្ញាធរក្រុងព្រះសីហនុ បានជួបបញ្ហាជាច្រើនករណី ពាក់ព័ន្ធទៅនឹងទំនាស់ដីធ្លី ពិសេសជាមួយភរិយា មន្ត្រីជាន់ខ្ពស់ និងនាយឧត្តមសេនីយ៍ ផ្កាយមាស៤ម្នាក់នៅក្រសួងការពារជាតិ ។

មន្ត្រីសាលាក្រុងព្រះសីហនុដដែល បានអោយដឹងទៀតថា កាលពីពាក់កណ្តាលឆ្នាំ២០០៧ មានភរិយា នាយឧត្តមសេនីយ៍ ផ្កាយមាស៤ម្នាក់ ឃុបឃិតជាមួយក្រុមហ៊ុនកូរ៉េមួយ គ្រោងអភិវឌ្ឍន៍ តំបន់មួយចំនួននៅក្រុងព្រះសីហនុ ។ ក្រុមហ៊ុនដែលអាងខ្នងភរិយានាយឧត្តមសេនីយ៍ផ្កាយមាស៤នោះ បានស្នើសុំដីរដ្ឋជាច្រើនកន្លែង និងក៏បានស្នើទិញដីរដ្ឋ ពីអាជ្ញាធរក្រុងព្រះសីហនុផងដែរ ប៉ុន្តែត្រូវអាជ្ញាធរក្រុង នៅក្រោមការដឹកនាំ របស់លោក*សាយ ហាក់* មិនឱ្យតាមបំណងព្រោះមានលោក*ពុត ចិន្តារិទ្ធ* អតីតអភិបាលខេត្តកំពត ជាប់ពន្ធនាគារម្តងហើយ ដោយសារតែរឿងដីធ្លីនេះ ។

ការជំទាស់ របស់អាជ្ញាធរក្រុងព្រះសីហនុ នៅពេលនោះបានធ្វើអោយភរិយានាយឧត្តមសេនីយ ផ្កាយមាស៤រូបនេះខឹង ហើយបានព្រមានថា នឹងស្នើមន្ត្រីជាន់ខ្ពស់ម្នាក់ នៅក្រសួងមហាផ្ទៃ អោយដកលោក*សាយ ហាក់* ចេញពីតំណែងអភិបាលក្រុងជាមិនខាន ។

ប្រភពបានឱ្យដឹងថា ភរិយានាយឧត្តមសេនីយ៍ ផ្កាយមាស៤រូបនោះ បានព្រមានអំពីការដកតំណែងលោក*សាយ ហាក់* នេះ ដែលធ្វើឱ្យលោកនាយករដ្ឋមន្ត្រី*ហ៊ុន សែន* ចេញសេចក្តីប្រកាសព័ត៌មានមួយថា គ្មានការផ្លាស់ប្តូរស្នងការស្នងការរងអភិបាល អភិបាលរង ខេត្តក្រុងទេ, ហើយសេចក្តីប្រកាសនោះក៏បានព្រមានចាប់ខ្លួនអ្នកដែលដើរនិយាយទៀតផង ។ ប៉ុន្តែមួយសប្តាហ៍ក្រោយពីការព្រមាននេះ ក៏មានពិធីផ្ទេរតំណែងអភិបាលក្រុងព្រះសីហនុរបស់លោក*សាយ ហាក់* ឱ្យទៅលោក*ស្បោង សារ៉ាត* ដែលប្រពន្ធរបស់គាត់ សំបូររឿងអាស្រូវទំនាស់ដីធ្លី នៃទីក្រុងទេសចរណ៍សមុទ្រមួយនេះ ។

ការផ្លាស់ប្តូរ តំណែងលោក*សាយ ហាក់* ពីអភិបាលក្រុងព្រះសីហនុនេះស្របពេលដែលលទ្ធផលផ្លូវការ នៃការបោះឆ្នោតបញ្ជាក់ថា គណបក្សប្រជាជន លួចបន្លំសន្លឹកឆ្នោតបាន៩០អាសនៈ ដែលការផ្លាស់ប្តូរនោះគឺអោយកូតាគណបក្សប្រជាជន ជាអភិបាលក្រុងព្រះសីហនុវិញ ។

គួរបញ្ជាក់ថា លោក*សាយ ហាក់* ត្រូវគេដឹងថា ជាប់សាច់ឈាម ជាមួយឧកញ៉ា*លី យ៉ុង ផាត់* ដែលជាមហាសេដ្ឋីដ៏មានប្រាក់ម្នាក់ និងជាអធិរាជ នៅតំបន់មាត់សមុទ្រ។ ការទទួលបានតំណែង ជាអភិបាលក្រុងព្រះសីហនុ របស់លោក *សាយ ហាក់* នេះ ក៏ត្រូវបានគេដឹងថាជាការថ្វាយស្រោមសំបុត្រ ដ៏ក្រាស់ក្រែល ពីអ្នកមានប្រាក់ម្នាក់ ថ្វាយសម្តេចក្រុមព្រះ កាលពីខែវិច្ឆិកា ឆ្នាំ២០០៤ ។

មន្ត្រីសាលាក្រុងព្រះសីហនុម្នាក់បានអោយដឹងថា លោក*សាយ ហាក់* កាន់តំណែង ជាអភិបាលក្រុង ព្រះសីហនុរយៈពេល៤ឆ្នាំនេះមានការអភិវឌ្ឍន៍ច្រើនគួរសម, ហើយសូម្បីតែសាលាក្រុង ដែលសម្ពោធ នៅថ្ងៃផ្ទេរតំណែងនោះក៏ជាស្នាដៃរបស់លោក*សាយ ហាក់* ដែរ។

មន្ត្រីសាលាក្រុង ដែលសុំមិនឱ្យបញ្ចេញឈ្មោះ បានឱ្យដឹងទៀតថាលោក*សាយ ហាក់* នឹងត្រូវគេរំពឹងថា នឹងទទួលបានតំណែង ជាអភិបាលក្រុងព្រះសីហនុបន្តទៀត តាមរយៈឧកញ៉ា*លី យ៉ុងផាត់* ដែលស្និទ្ធជាមួយលោក*ហ៊ុន សែន* ។ តែលោក*សាយ ហាក់* មានបញ្ហាដីធ្លី ជាមួយក្រុមហ៊ុន ដែលមានភាគហ៊ុន ជាមួយភរិយានាយឧត្តមសេនីយ៍ ផ្កាយមាស៤ម្នាក់នោះ បានធ្វើឱ្យលោក*សាយ ហាក់* មិនអាចទប់ជាប់ ក៏ផ្ទេរឱ្យលោក*ស្បោង សារ៉ាត* ជាអភិបាលក្រុងវិញ ។

អ្នកស្និទ្ធលោក*សាយ ហាក់* នៅសាលាក្រុងព្រះសីហនុបាននិយាយអួតអាងអំពីស្នាដៃនិងការខំប្រឹងប្រែង របស់លោក*សាយ ហាក់* ។ ប៉ុន្តែក្រុមគាំទ្រលោក*ស្បោង សារ៉ាត* ជាអតីត អភិបាលរងក្រុងព្រះសីហនុវិញបានរិះគន់លោក*សាយ ហាក់* យ៉ាងខ្លាំង ថាពាក់ព័ន្ធនឹងអំពើពុករលួយ ។

ទោះជាយ៉ាងណា ការដកលោក*សាយ ហាក់* ដាក់លោក*ស្បោង សារ៉ាត* នេះ ត្រូវបានគេដឹងថាគឺពាក់ព័ន្ធនឹងគាត់មិនប្រគល់ដីរដ្ឋ អោយក្រុមហ៊ុនឯកជនមួយដែលមានភាគហ៊ុនជាមួយភរិយា នាយឧត្តមសេនីយ៍ផ្កាយមាស៤ម្នាក់ នៅក្រសួងការពារជាតិ, ហើយនាយឧត្តមសេនីយ៍នោះ ត្រូវបានគេដឹងថា ស្និទ្ធស្នាលជាមួយមន្ត្រីជាន់ខ្ពស់ម្នាក់ នៅក្រសួងមហាផ្ទៃទៀតផង ។

គួររំលឹកថា កាលពីដើមឆ្នាំ២០០៧ មានប្រជាពលរដ្ឋរាប់រយនាក់ មកតវ៉ានៅមុខទីស្តីការគណៈរដ្ឋមន្ត្រី ប្រឆាំងនឹងក្រុមហ៊ុនមួយ ដែលមានភាគហ៊ុនជាមួយភរិយា លោក*កែ គឹមយ៉ាន* អគ្គមេបញ្ជាការ នៃកងយោធពលខេមរភូមិន្ទ ។ ក្រោយពីការតវ៉ានោះ បានធ្វើឱ្យលោក*ហ៊ុន សែន* ធ្វើអន្តរាគមន៍ភ្លាម១ផងដែរ ដើម្បីចង់បានសន្លឹកឆ្នោត ៕

**តមកពីទំព័រ១ ខ**

ប្រគល់ ដីគ្រោងធ្វើទីស្នាក់ការគណបក្សហ៊្វុនស៊ិនប៉ិចជាង១០ហិកតា នៅជាយក្រុងភ្នំពេញឱ្យទៅហ៊្វុនស៊ិនប៉ិចវិញទេ ។

ចំពោះមន្ត្រី របស់គណបក្សនរោត្តម រណឫទ្ធិមួយចំនួននៅទីក្រុងភ្នំពេញ កំពុងជ្រួលច្របល់ព្រោះខ្លាចមិនបានចូលរដ្ឋាភិបាលបន្ទាប់ពីឮលោកនាយករដ្ឋមន្ត្រី*ហ៊ុន សែន* អះអាងនៅទីស្តីការ ក្រសួងការបរទេស កាលពីព្រឹកថ្ងៃច័ន្ទថា រាជរដ្ឋាភិបាលថ្មី នឹងបង្កើតនៅថ្ងៃទី២៥ ខែកញ្ញា ២០០៨ ។

ថ្នាក់ដឹកនាំម្នាក់ របស់គណបក្សនរោត្តម រណឫទ្ធិ បានឱ្យដឹងថា លោក*ជា ច័ន្ទបរិបូរណ៍* ដែលកំពុងសកម្ម ក្នុងការទាក់ទង ជាមួយលោក*ហ៊ុន សែន* ដើម្បីសុំភ្លើងខៀវ ឱ្យសម្តេចក្រុមព្រះមានលទ្ធភាពយាងត្រឡប់ចូលស្រុកវិញ នៅក្រោយការបង្កើតរដ្ឋាភិបាល អាណត្តិទី៤ហើយ ។ ការទាក់ទងនោះមិនត្រូវលោក*ហ៊ុនសែន*ជំទាស់អ្វីទេ ដោយគ្រាន់តែឱ្យសម្តេចក្រុមព្រះ ដោះស្រាយជាមួយគណបក្សហ៊្វុនស៊ិនប៉ិច រួចរាល់សិន ពិសេសព្រះអង្គប្រគល់ដីជាង១០ហិកតាគ្រោងធ្វើស្នាក់ការហ៊្វុនស៊ិនប៉ិចដែលតម្លៃទៅតាមទីផ្សារសេរីសព្វថ្ងៃ ជាង១០លានដុល្លារអោយទៅគណបក្សហ៊្វុនស៊ិនប៉ិចវិញ ។ ការដែលព្រះអង្គ មិនទាន់បានប្រគល់ដី ជាង១០ហិកតាអោយមកភាគីហ៊្វុនស៊ិនប៉ិចនេះ វាជារនាំង នៃការទប់ស្កាត់ព្រះអង្គម្ចាស់ *រណឫទ្ធិ* មិនអាចអោយយាងត្រឡប់ចូលស្រុកវិញបានតាមគំរោងឡើង ។

ក្រោយពី សម្តេចក្រុមព្រះប្រកាសទទួលស្គាល់ លទ្ធផលបោះឆ្នោតមក លទ្ធភាពនៃការយាងត្រឡប់ មកស្រុកវិញមិនបញ្ហាទេ, ប៉ុន្តែបញ្ហាដែលមានដូចសព្វថ្ងៃនោះ គឺដោយសារព្រះអង្គលោភលន់ ចង់បានប្រយោជន៍ច្រើន តាមការស្នើសុំតួនាទី នៅក្នុងរដ្ឋាភិបាលនោះបានធ្វើឱ្យលោក*ហ៊ុន សែន* ខឹង ហើយក៏ឈប់និយាយ ជាមួយព្រះអង្គមួយរយៈពេល ។ តែឥឡូវបញ្ហាសំរាប់ព្រះអង្គនោះគឺបញ្ហាដី គ្រោងធ្វើទីស្នាក់ការគណបក្សហ៊្វុនស៊ិនប៉ិចនៅជាយក្រុងភ្នំពេញ ។

ដីកម្មសិទ្ធិរបស់ហ៊្វុនស៊ិនប៉ិចជាង១០ហិកតា ដែលបានមកពីសម្តេចក្រុមព្រះ លក់ដីអតីតទីស្នាក់ការ នៅក្បែរគល់ស្ពានជ្រោយចង្វារនោះយកទៅទិញនៅជាយក្រុងភ្នំពេញ ជាង១០ហិកតា ក្នុងគោលបំណង ធ្វើទីស្នាក់ការកណ្តាល ។ សម្តេចក្រុមព្រះ បានដាក់ឈ្មោះដីទីស្នាក់ការហ៊្វុនស៊ិនប៉ិចនោះ ជាកម្មសិទ្ធិរបស់ព្រះអង្គ ដែលជាហេតុ ធ្វើឱ្យហ៊្វុនស៊ិនប៉ិច គ្មានទីស្នាក់ការ ក៏ប្តឹងព្រះអង្គទៅតុលាការ, ហើយតុលាការបានកាត់ទោស ឱ្យព្រះអង្គជាប់ពន្ធនាគារ១៨ខែ ពិន័យជាប្រាក់១០ម៉ឺនដុល្លារ និងប្រគល់ដីឱ្យទៅហ៊្វុនស៊ិនប៉ិចវិញ ។

មន្ត្រីដែលស្និទ្ធ នឹងសម្តេចក្រុមព្រះ បានអោយដឹងទៀតថា ព្រះអង្គបានធ្វើអ្វី១ទៅតាមលោក*ហ៊ុន សែន* ទាំងអស់នៅក្រោយការបោះឆ្នោតនេះ ដូចជាទទួលស្គាល់ លទ្ធផលនៃការបោះឆ្នោត, ការដកលោក*មុត ចន្ថា* ពីអ្នកនាំពាក្យ ។ ប៉ុន្តែលោក*ហ៊ុន សែន* មិនទាន់យល់ព្រម ឱ្យទ្រង់យាងត្រឡប់ចូលស្រុកវិញទេ ដោយអោយដោះស្រាយបញ្ហាដីធ្លី ជាមួយគណបក្សហ៊្វុនស៊ិនប៉ិច រួចរាល់សិន, ពិសេស ទាល់តែសម្តេចក្រុមព្រះ យល់ព្រមប្រគល់ដីគ្រោងធ្វើស្នាក់ការ គណបក្សហ៊្វុនស៊ិនប៉ិច ជាង១០ហិកតានៅជាយក្រុងភ្នំពេញនោះ អោយទៅគណបក្សហ៊្វុនស៊ិនប៉ិចវិញ ។

ពាក់ព័ន្ធទៅនឹងបញ្ហាផ្ទៃក្នុងវិញគណបក្សនរោត្តម រណឫទ្ធិ ដែលជាគណបក្សដ៏តូចនេះ ក៏ប្រឈមបញ្ហាខ្លះដែរ ពិសេសនៅពេលសម្តេចក្រុមព្រះយល់ព្រមតាមលោក*ហ៊ុន សែន* ដកលោក*មុត ចន្ថា* ពីអ្នកនាំពាក្យចេញដែលការអត្តនោម័តរបស់សម្តេចក្រុមព្រះនេះ បានធ្វើឱ្យអ្នកចាសទុំប៉ុន្មាននាក់ដែលនៅដង្ហែព្រះអង្គ សំដែងការហួសចិត្តយ៉ាងខ្លាំង ដោយពួកគេអះអាងថា សម្តេចក្រុមព្រះ នៅតែទន់ជ្រាយ, ហើយអោយតែសត្រូវ(ហ៊ុន សែន) បញ្ជោរតែបន្តិចនោះ ទ្រង់ស៊ីជោរភ្លាមគឺអត់ចេះគិតអ្វីដែលខុស ឬត្រូវ ចំណេញឬខាតសំរាប់គណបក្សឬជាតិនោះទេ ។

ប្រភពបានឱ្យដឹងថា លោក*មុត ចន្ថា* កំពុងតែព្រួយបារម្ភនឹងសម្តេចក្រុមព្រះ ដកចេញពីនាយខុទ្ទកាល័យ របស់ព្រះអង្គទៀតដើម្បីយកទៅប្រគល់ឱ្យលោក*អាណាន់ ដាយ៉ាត* ឬលោក*ជា ច័ន្ទបរិបូរណ៍* ។ រីឯលោក*សៅ រ៉ានី* វិញ អត់ខ្វល់អ្វីទាំងអស់ គឺរង់ចាំតែសម្តេចក្រុមព្រះអាចយាងត្រឡប់ចូលស្រុកវិញបាន ទៅចរចាជាមួយលោក*ហ៊ុន សែន* ដើម្បីបានតំណែងខ្លះ នៅក្នុងរដ្ឋាភិបាល ។

តែមាន សេចក្តីរាយការណ៍ថា សម្តេចក្រុមព្រះ បានព្រមានមន្ត្រីព្រះអង្គ មិនឱ្យនាំគ្នានិយាយអំពីការចូលរដ្ឋាភិបាលអ្វីទេ ហើយព្រះអង្គត្រៀមនឹងធ្វើអ្វី១គ្រប់យ៉ាង តាមការចង់បានរបស់លោក*ហ៊ុន សែន* ។

ទោះយ៉ាងណា សម្តេចក្រុមព្រះ នៅតែរារែកចំពោះការស្នើសុំ របស់លោក*ហ៊ុន សែន* អោយព្រះអង្គ វិលត្រឡប់ទៅធ្វើជាប្រធាន ហ៊្វុនស៊ិនប៉ិចវិញ ដែលសំណើ របស់លោក*ហ៊ុន សែន* នេះ ត្រូវថ្នាក់ដឹកនាំគណបក្សនរោត្តម រណឫទ្ធិ ពន្យល់សម្តេចក្រុមព្រះថា លោក*ហ៊ុន សែន* បង្ខំឱ្យព្រះអង្គ សោយព្រះកំហាកខ្លួនឯងហើយ។ ប្រភពបានបន្តថា បើសិនជាព្រះអង្គ យល់ព្រមមកដឹកនាំគណបក្សហ៊្វុនស៊ិនប៉ិចវិញនោះ ប្រមុខរដ្ឋាភិបាល អាចនឹងអោយតំណែង គណៈរដ្ឋមន្ត្រីខ្លះ សំរាប់គណបក្សនរោត្តម រណឫទ្ធិ គឺអាចអោយព្រះអង្គ មានលទ្ធភាពយកតំណែងទាំងនោះទៅលក់ ដូរយកស្រោមសំបុត្រដូចដែលទ្រង់ ធ្លាប់ធ្វើក្រោយការបោះឆ្នោតជាតិ នាពេលកន្លងមកដែរ ។

គេថា ឃីអ៊ុនសម្តេចក្រុមព្រះនៅស្រុតចុះនៅឡើយទេ។ ដូច្នេះការស្រមើលស្រមៃរបស់ទ្រង់ នៅតែជាការស្រមើស្រមៃសុទ្ធសាធមិនអាចក្លាយទៅជាការពិតបានឡើយដរាបណាទ្រង់មិនព្រមប្រគល់នូវអ្វីដែលទ្រង់បានជំពាក់ហ៊្វុនស៊ិនប៉ិច ជាមុនទេនោះ ៕

**តមកពីទំព័រ១ ស**

លោក *ហ៊ុន សែន* ដោយត្រង់១ និងធ្លាប់ធ្វើឱ្យលោក *ហ៊ុន សែន* ឈឺក្បាលជាបន្តបន្ទាប់នោះ បានប្រកាសលាលែងពីតំណែង របស់លោកកាលពីថ្ងៃច័ន្ទ ដើមសប្តាហ៍នេះហើយ ។

ទោះជាដូច្នេះក្តី ក៏លោក*យ៉ាស្ហ ហ្គាយ* បានអំពាវនាវតាមសេចក្តីថ្លែងការណ៍របស់លោកយ៉ាងម៉ឺងម៉ាត់នៅចំពោះមុខក្រុមប្រឹក្សាសិទ្ធិមនុស្សអន្តរជាតិនៅទីក្រុងហ្សឺណែវដោយជម្រុញឱ្យផ្នែកសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ បន្តអាណត្តិនៅក្នុងប្រទេសកម្ពុជាដើម្បីជួយដល់ប្រជាពលរដ្ឋខ្មែរដែលត្រូវគេរំលោភសិទ្ធិយ៉ាងកម្រោលព្រៃផ្សៃបំផុត។

គួរបញ្ជាក់ថាលោក *យ៉ាស្ហ ហ្គាយ* បានជំនួសការងារលោក*ភីតធី ឡឺប្រិច* អតីតប្រេសិតពិសេសរបស់ អ.ស.ប ទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា កាលពីឆ្នាំ២០០៥ បន្ទាប់ពីប្រេសិតរូបនេះមិនត្រូវរ៉ូវគ្នាជាមួយរដ្ឋាភិបាលលោក *ហ៊ុន សែន* ក្នុងការរិះគន់បញ្ហារំលោភសិទ្ធិមនុស្សយ៉ាងធ្ងន់ធ្ងរនៅក្នុងប្រទេសកម្ពុជានោះ។

លោក *យ៉ាស្ហ ហ្គាយ* បានអះអាងថា តាមសេចក្តីថ្លែងការណ៍របស់លោកកាលពីថ្ងៃច័ន្ទ នៅទីក្រុងហ្សឺណែវថា "*រដ្ឋាភិបាលកម្ពុជាតែងតែជំទាស់នឹងការងាររបស់ប្រេសិតសិទ្ធិមនុស្ស អ.ស.ប ចំនួន៤រូបរួចមកហើយ* "។

យ៉ាងណាក៏ដោយ លោក*យ៉ាស្ហហ្គាយ*បានមានប្រសាសន៍ថា "*មានភាពប្រសើរឡើងតិចតួចប៉ុណ្ណោះដែលគេមើលឃើញនៅក្នុងប្រទេសកម្ពុជា ពោលគឺមិនមែនមានន័យថា មិនអាចប្រែប្រួលបានដោយសារតែកង្វះខាតប្រព័ន្ធយ៉ាងជ្រៅនៅក្នុងតុលាការ និងស្ថាប័នសំខាន់១ផ្សេងទៀត អនុវត្តតាមនីតិវិធីច្បាប់និងការពារសិទ្ធិរបស់មនុស្សម្នាក់១ឡើយ* "។

ក្នុងនោះលោក*យ៉ាស្ហហ្គាយ*នៅបានគូសបញ្ជាក់ផងដែរថា "*សហគមន៍អន្តរជាតិបានទុកឱ្យរូបលោកប្រឈមតែម្នាក់ឯងនឹងសង្គ្រាមពាក្យសម្តីជាមួយរដ្ឋាភិបាលក្រុងភ្នំពេញ* "។

ជាងនេះទៀតលោក*យ៉ាស្ហ ហ្គាយ*បានមានប្រសាសន៍ដោយត្រង់១ថា"*វាជាសារសំខាន់បំផុតហើយដែលអ្នកស្នងតំណែងរបស់ខ្ញុំគួរតែមានការគាំទ្រឱ្យបានពេញលេញពីក្រុមប្រឹក្សាសិទ្ធិមនុស្សអន្តរជាតិនេះ ពិសេសគឺមានការគាំទ្រពីគ្រួសារសហប្រជាជាតិ និងសហគមន៍អន្តរជាតិ* "។

លោក *យ៉ាស្ហ ហ្គាយ* បានថ្លែងតាមរបៀបចំអកឡកឡឺយថា "*ខ្ញុំមិនអាចនិយាយថា ខ្ញុំមានការគាំទ្រច្រើនបែបនេះឡើយ ហើយនេះវាគ្រាន់តែជាការលើកទឹកចិត្តលោក ហ៊ុន សែននាយករដ្ឋមន្ត្រីរបស់ប្រទេសកម្ពុជាឱ្យប្រមាថខ្ញុំឥតឈប់ឈរតែប៉ុណ្ណោះ* "។

លោក *យ៉ាស្ហ ហ្គាយ* បាននិយាយដោយគ្មានលាក់លៀមថា "*លោក ហ៊ុន សែន បានហៅខ្ញុំថាភ្លីភ្លើ, ទេសចររយៈពេលខ្លីខ្លិល។ រីឯលោក ខៀវ កាញារីទ្ធ អ្នកនាំពាក្យរដ្ឋាភិបាលវិញបានហៅខ្ញុំថា គ្មានអារ្យធម៌ និង ខ្វះវប្បធម៌អំបូរAryan*"។

លោក *ហ្គាយ* បានអត្ថាធិប្បាយបន្ថែមថា "*លោក ហ៊ុន សែន ក៏បានចោទខ្ញុំផងដែរពីបទនិយាយកុហក និងការតែងតាំងខ្ញុំឡើងនេះ ដើម្បីតែទទួលប្រាក់ខែ ។មិនតែប៉ុណ្ណោះលោក ហ៊ុន សែនបានពណ៌នាពីអង្គការសិទ្ធិមនុស្សអន្តរជាតិ និងខ្លួនខ្ញុំផ្ទាល់ថា ធ្វើដូចជាសត្វ ។ លោកបានបង្អាប់ប្រទេសកេនយ៉ារបស់ខ្ញុំថាប្រទេសនេះកំពុងក្លាយជាវាលពិឃាត, ហើយលោក ខៀវ កាញារីទ្ធ បាននិយាយថាប្រជា ជនកេនយ៉ាគ្រោតគ្រាតនិង ឃោរឃៅ* "។

ទំនងជាហួសចិត្តនឹងភាពស្ងៀមស្ងាត់របស់ក្រុមប្រឹក្សាសិទ្ធិមនុស្សអន្តរជាតិនៅក្រុងហ្សឺណែវហើយមើលទៅ ទើបលោក*យ៉ាស្ហហ្គាយ* បានបញ្ជាក់យ៉ាងដូច្នេះថា "*ការិយាល័យឧត្តមស្នងការសម្រាប់សិទ្ធិមនុស្សនៅក្រុងហ្សឺណែវ មិនបានជួយការពារខ្ញុំទេ ហើយក៏បានបដិសេធមិនចេញសេចក្តីថ្លែងការណ៍ពន្យល់ថាខ្ញុំមិនបានទទួលប្រាក់ខែឡើយ។ ដូច្នេះខ្ញុំត្រូវតែបង្ខំចិត្តលើកឡើងដោយច្បាស់១ក្នុងនាមខ្លួនខ្ញុំផ្ទាល់* "។

សេចក្តីថ្លែងរបស់លោក*យ៉ាស្ហ ហ្គាយ* នៅទីក្រុងហ្សឺណែវ កាលពីថ្ងៃច័ន្ទកន្លងទៅនោះ មិនទាន់មានប្រតិកម្មណាមួយពីមន្ត្រីរដ្ឋាភិបាលក្រុងភ្នំពេញឡើយកាលពីម្សិលមិញ។

ប៉ុន្តែតាងនាមឱ្យសហភាពអឺរ៉ុបលោក Jean Baptiste Mattei ឯកអគ្គរដ្ឋទូតប្រទេសបារាំងបានថ្លែងថា "*សហភាពអឺរ៉ុបសាទរចំពោះការសម្រេចចិត្តរបស់ប្រទេសកម្ពុជាក្នុងការទទួលយកការបន្តអាណត្តិនៃប្រេសិតរបស់អគ្គលេខាធិការ អ.ស.ប ទទួលបន្ទុក ផ្នែកសិទ្ធិមនុស្សប្រចាំកម្ពុជាតទៅទៀត*"។

ចំណែកលោកស្រី Juilette de Rivero នាយិកាអង្គការឃ្លាំមើលសិទ្ធិមនុស្សដែលមានមូលដ្ឋាននៅទីក្រុងហ្សឺណែវដែលបានថ្លែងទៅកាន់ក្រុមប្រឹក្សាសិទ្ធិមនុស្សកាលពីថ្ងៃច័ន្ទ ក៏បានសម្តែងពីការគាំទ្រការបន្តអាណត្តិនេះដែរ។

ប៉ុន្តែលោកស្រី បានមានប្រសាសន៍ថា "*នៅក្នុងបែបបទបច្ចុប្បន្ន របស់ក្រុមប្រឹក្សាសិទ្ធិមនុស្សដំណោះស្រាយនឹងផ្លាស់ប្តូរតំណែងពីតំណាងពិសេសប្រចាំនៅកម្ពុជាដែលត្រូវបានតែងតាំងដោយក្រុមប្រឹក្សាសិទ្ធិមនុស្សវិញ ដែលបញ្ហានេះគឺជាការផ្លាស់ប្តូរស្របទៅតាមកំណែប្រែត្រូវបានធ្វើចំពោះអាណត្តិនៅក្នុងបណ្តាប្រទេសភាគច្រើន*"។

យ៉ាងណាក៏ដោយក៏លោកស្រី Juilette de Rivero បានវាយតម្លៃថា ប្រទេសកម្ពុជាមានបញ្ហាជាមួយមន្ត្រីសិទ្ធិមនុស្ស អ.ស.បដែលជាអ្នកកាន់អាណត្តិ មែនតែពួកគេក៏ចង់បន្តអាណត្តិនេះតទៅទៀតដែរ។

គួររំលឹកថា សង្គ្រាមពាក្យសម្តីរវាងលោក *យ៉ាស្ហ ហ្គាយ* និងលោក *ហ៊ុន សែន* បានធ្វើឱ្យសាធារណមតិគ្រប់មជ្ឈដ្ឋានរិះគន់លោក *ហ៊ុន សែន* យ៉ាងកងរំពងថា ប្រការដែលរដ្ឋាភិបាលលោក *ហ៊ុន សែន* មិនព្រមសហការជាមួយលោក*យ៉ាស្ហ ហ្គាយ* នោះ គឺបានត្រឹមតែធ្វើឱ្យកេរ្តិ៍ឈ្មោះលោក *ហ៊ុន សែន* កាន់តែអាក្រក់ទៅ១ប៉ុណ្ណោះ។ ហើយប្រសិនបើរដ្ឋាភិបាលនេះបញ្ចប់អាណត្តិការិយាល័យឧត្តមស្នងការសិទ្ធិមនុស្ស អ.ស.ប ប្រចាំនៅកម្ពុជាមែននោះ គេជឿថា អំពើរំលោភសិទ្ធិមនុស្សនឹងរីករាលដាលច្រើនជាងសព្វថ្ងៃនេះរាប់រយដងទៅទៀត៕

**តមកពីទំព័រ១ ខ**

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុរកវិធីបញ្ចុះតម្លៃប្រេងឥន្ធនៈដើម្បីឱ្យស្របតាមតម្លៃទីផ្សារអន្តរជាតិ។

គួរបញ្ជាក់ថា តម្លៃប្រេងឥន្ធនៈលើទីផ្សារអន្តរជាតិបានធ្លាក់ចុះប្រមាណ២៥ភាគរយទៅហើយ តែបែរជាតម្លៃប្រេងឥន្ធនៈនៅកម្ពុជាដែលជាប្រទេសក្រីក្រជាប់ចំណាត់ថ្នាក់ពិភពលោកវិញ នៅតែមានតម្លៃខ្ពស់ដដែល គ្មានការស្រកស្រុតទៅតាមតម្លៃទីផ្សារអន្តរជាតិទាល់តែសោះ។

កាលពីថ្ងៃទី១៥ ខែកញ្ញាកន្លងទៅ នាយករដ្ឋមន្ត្រី *ហ៊ុន សែន* ដែលប្រជាពលរដ្ឋខ្មែរស្គាល់ថា ជានាយករដ្ឋមន្ត្រីល្មោភអំណាចផុតលេខនៅស្រុកខ្មែរនោះ បានប្រកូកប្រកាសដោយអំណួតនៅចំពោះមុខអ្នកកាសែតជាតិ និងអន្តរជាតិថា គាត់នឹងបញ្ជាឱ្យរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដោះស្រាយបញ្ហាបញ្ចុះតម្លៃប្រេងសាំង។

អ្នកកាន់អំណាចមិនស្កប់ស្កល់ម្នាក់នេះបាននិយាយយ៉ាងដូច្នេះថា"*ខ្ញុំបញ្ជាឱ្យរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុធ្វើការតែម្តង ។នៅពេលមុននេះខ្ញុំបានកត់សម្គាល់ហើយគឺតម្លៃប្រេងធ្លាក់ចុះ ហើយបើយើងពិនិត្យមើលនៅក្នុងអាទិត្យចុងក្រោយនេះ តម្លៃនៅលើទីផ្សារពិភពលោកធ្លាក់ប្រមាណ២៥ភាគរយទៅហើយ ឯកម្ពុជាវិញទើបនឹងធ្លាក់តម្លៃក្នុងរង្វង់តែ១០ភាគរយប៉ុណ្ណឹងទេ ដូច្នេះវាមិនទាន់សមស្របគ្នា*"។

នាយករដ្ឋមន្ត្រី *ហ៊ុន សែន* បានបន្តទៀតថា"*យើងសម្តែងនូវការយោគយល់ចំពោះក្រុមហ៊ុនទាំងឡាយដែលធ្លាប់ទិញប្រេងក្នុងតម្លៃខ្ពស់ ហើយនៅអាទិត្យចុងក្រោយនេះលក់មិនទាន់អស់ ។ តែខ្ញុំក៏សុំសរសើរចំពោះក្រុមហ៊ុនសូគីម៉ិចដែលមានតម្លៃទាបជាងគេក្នុងពេលនេះ ខណៈដែលក្រុមហ៊ុនមួយចំនួនផ្សេងទៀតរាប់ទាំងក្រុមហ៊ុនបរទេសមានតូតាល់, កាល់តិច ជាដើម នៅមានតម្លៃខ្ពស់ដដែល*"។

លោក *ហ៊ុន សែន* បានលើកឡើងថា"*ខ្ញុំសូមអំពាវនាវឱ្យបន្តយកវិធានការទម្លាក់តម្លៃប្រេងឥន្ធនៈចុះបន្ថែមទៀត*"។

ក្នុងនោះលោក *ហ៊ុន សែន* បានសង្កត់ធ្ងន់ថា "*កន្លងមកយើងយោគយល់ថា នៅពេលដែលប្រេងនៅសហរដ្ឋអាមេរិកធ្លាក់ថ្លៃប្រមាណ១០ភាគរយ យើងមិនតម្រូវឱ្យតម្លៃប្រេងនៅកម្ពុជាចុះថ្លៃ១០ភាគរយភ្លាមៗទេ។ ប៉ុន្តែតម្លៃប្រេងនៅលើពិភពលោកវាបានចុះថ្លៃប៉ុន្មានអាទិត្យរួចមកហើយ។ ដូច្នេះតម្លៃប្រេងនៅកម្ពុជាវាត្រូវតែចុះជាងនេះទៀត*"។

គួររំលឹកថា តម្លៃប្រេងនៅទីក្រុងឡុងដ៍បានធ្លាក់ចុះមកនៅក្រោម១០០ដុល្លារក្នុង១ធុងនៅថ្ងៃទី៩ ខែកញ្ញា ហើយបានបន្តចុះថ្លៃបន្ថែមទៀតមកដល់ពេលនេះ។ មុននេះតម្លៃប្រេងខ្ពស់បំផុត គឺស្មើនឹងជាង១៤៧ដុល្លារក្នុង១ធុងដែលបង្ហាញថាប្រេងឆៅបានចុះថ្លៃប្រមាណជាង៤០ដុល្លារអាមេរិកក្នុង១ធុង គឺប្រមាណជាង២៧ភាគរយ។

ចំណែកនៅកម្ពុជាវិញប្រេងឡើងថ្លៃខ្ពស់បំផុត គឺ៥៦០០រៀលក្នុង១លីត្រ តែពេលនេះគេបញ្ចុះតម្លៃមកនៅត្រឹម៥១០០រៀលក្នុង១លីត្រប៉ុណ្ណោះ។បានន័យថាតម្លៃប្រេងនៅក្នុងប្រទេសកម្ពុជានៅតែខ្ពស់ជាងគេដដែល។

ទាក់ទិននឹងតម្លៃប្រេងនៅកម្ពុជា នៅតែរក្សាថ្លៃខ្ពស់កប់ពពកបែបនេះត្រូវបានមជ្ឈដ្ឋាននានាលើកឡើងថាមកពីលោក *គាត ឈន់* រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុអសមត្ថភាពពេក ទើបក្រុមហ៊ុនរកស៊ីប្រេងឥន្ធនៈនៅក្នុងស្រុកខ្មែរអាចធ្វើព្យុះ ធ្វើភ្លៀងតាមតែអំពើចិត្តដូច្នេះ។

ប៉ុន្តែក្រុមអ្នកសេដ្ឋកិច្ចឯករាជ្យបានពន្យល់ថា ប្រសិនបើរដ្ឋាភិបាលលោក *ហ៊ុន សែន* បញ្ចុះតម្លៃពន្ធប្រេងឱ្យទាបតែបន្តិច តម្លៃប្រេងនៅក្នុងស្រុកខ្មែរក៏ត្រូវតែចុះថ្លៃភ្លាមៗដែរ។ អញ្ចឹងទេ រឿងប្រេងចុះថ្លៃ ឬមិនចុះថ្លៃនេះវាស៊ីសងលើចំណាត់ការរបស់រដ្ឋាភិបាលខ្លួនឯង ហើយពិសេសគឺលោក *គាត ឈន់* ហ្នឹងតែម្តង ដែលត្រូវតែបញ្ចុះតម្លៃពន្ធប្រេងឱ្យនៅទាបវាប្រសើរជាងឆ្លើយទម្លាក់កំហុសទៅលើក្រុមហ៊ុនរកស៊ីប្រេងនៅស្រុកខ្មែរ។

ម្យ៉ាងទៀតគេអាចយល់បានថា ការបញ្ជាឱ្យលោក *គាត ឈន់* ចាត់វិធានការបញ្ចុះតម្លៃប្រេងឥន្ធនៈដោយបុរសខ្លាំង *ហ៊ុន សែន* នេះ គឺបណ្តាលមកពីនាយករដ្ឋមន្ត្រីម្នាក់ហ្នឹងខ្មាស់នឹងការអត្ថាធិប្បាយ របស់លោក *សុន ឆ័យ* អ្នកនាំពាក្យគណបក្សសមរង្ស៊ីដែលបានលើកឡើងថា ថ្លៃប្រេងនៅកម្ពុជាពេលនេះគួរតែមានតម្លៃត្រឹម៣៨០០រៀលក្នុង១លីត្រ។

គួរបញ្ជាក់ផងដែរថាលោក*សុនឆ័យសមាជិកសភាមណ្ឌលភ្នំពេញនិងជាអ្នកនាំពាក្យគណបក្សសមរង្ស៊ីបានប្រាប់ខ្មែរម្ចាស់ស្រុក* កាលពីពេលកន្លងទៅថា "*យើងមានការព្រួយបារម្ភ និងមិនសប្បាយចិត្ត ចំពោះស្ថានភាពអំពីតម្លៃប្រេង ដូចបងប្អូនជនរួមជាតិយើងដូច្នោះដែរ ។ យើងបាន ឃើញថាតម្លៃប្រេងនៅកម្ពុជាដែលបានឡើងថ្លៃរហូតដល់៥៧០០រៀល ក្នុងមួយលិត្រ នោះនៅពេលដែលតម្លៃប្រេងលើទីផ្សារអន្តរជាតិឡើងដល់១៤៨ដុល្លារក្នុងមួយធុង។ តែឥឡូវនេះតម្លៃប្រេងធ្លាក់មកនៅក្រោម១០០ដុល្លារ ហើយ ក្នុងមួយធុងគឺបានន័យថាធ្លាក់តម្លៃមួយភាគបីហើយ*"។

លោក*សុន ឆ័យ* បានថ្លែងថា បើតាមតម្លៃទីផ្សារសេរីគឺទីផ្សារប្រេងនៅប្រទេសកម្ពុជាត្រូវតែបញ្ចុះតម្លៃ អោយនៅយ៉ាងខ្ពស់បំផុត ៣.៨០០រៀលក្នុងមួយលីត្រ។ លោកបានបន្តថា រដ្ឋាភិបាលនិយាយគ្មានការពិតទេ ដែលកន្លងទៅមន្ត្រីរដ្ឋាភិបាលនិយាយថា មិនអាចទប់តម្លៃប្រេងឡើងថ្លៃបានទេ ពីព្រោះការឡើងនេះគឺឡើងតាមតម្លៃទីផ្សារអន្តរជាតិ ។ ប៉ុន្តែឥឡូវ ទីផ្សារអន្តរជាតិ បានចុះមួយភាគបីហើយ ហេតុអ្វីបានជាទីផ្សារនៅកម្ពុជា មិនព្រមចុះថ្លៃ ដែលនេះជាការកេងប្រវ័ញ្ច និងហុតឈាមប្រជាពលរដ្ឋខ្មែរ។ លោក*សុន ឆ័យ* បានមានប្រសាសន៍ថា ក្រុមហ៊ុនប្រេងមួយចំនួននៅកម្ពុជា គឺគេបានទិញប្រេងស្តុកទុកច្រើន ដែលគេទិញនោះ តាំងពីនៅតម្លៃថោកប៉ុន្តែគេតម្លើងថ្លៃភ្លាមឱ្យស្របតាមទីផ្សារពិភពលោកដែរ, តែនៅពេលទីផ្សារពិភពលោកចុះថ្លៃមកវិញ គេមិនចុះទេ ដោយគេយកលេសថា គេទិញស្តុកទុកនោះកាលពីនៅថ្លៃ ។

លោក*សុន ឆ័យ* បានរិះគន់រដ្ឋាភិបាលថាមិនបានពិនិត្យឱ្យបានត្រឹមត្រូវ ចំពោះការលក់ប្រេងនៅលើទីផ្សារសេរី ថាតើប្រេងចាស់ ឬប្រេងទើបតែនាំចូលថ្មី ដើម្បីកុំឱ្យឈ្មួញចេះតែតម្លើងតម្លៃប្រេង តាមតែចិត្តនោះ ។ លោកបានបន្តថា ការដែលរដ្ឋាភិបាលមិនធ្វើការត្រួតពិនិត្យ ឱ្យក្រុមហ៊ុនបញ្ចុះតម្លៃប្រេង ឱ្យស្របទៅតាមទីផ្សារអន្តរជាតិនេះ វាជាការបង្ហាញឱ្យឃើញ អំពីការគ្រប់គ្រងប្រទេសបែបអនាធិបតេយ្យដែលនាំឱ្យជួបការលំបាក ដល់ប្រជាពលរដ្ឋ ។

ចំពោះសំណួរ ដែលសួរថាតើគណបក្សសម រង្ស៊ី នឹងមានវិធានការបែបណាដែរ ដើម្បីជម្រុញអោយរដ្ឋាភិបាលបញ្ចុះតម្លៃប្រេង ស្របទៅតាមទីផ្សារពិភពលោកនោះ ? លោក*សុន ឆ័យ* បានមានប្រសាសន៍ថា "*ជាគោលការណ៍យើងត្រូវតែអោយមានការឆ្លើយឆ្លងគ្នាពន្យល់គ្នាពីព្រោះនៅក្នុងស្ថានភាពនៃការគ្រប់គ្រងមួយដែលមិនមានការតាមដាន និងឱ្យមានការសួរដេញដោលនេះ គឺអ្នកកាន់អំណាចត្រូវគ្នាជាមួយនឹងឈ្មួញ គឺគេកាងការពារនិងកេងបំបាត់ ដោយតម្លើងតម្លៃខ្ពស់នេះដើម្បីផលប្រយោជន៍, ហើយយើង នឹងហែកកកាយការពិត ពីព្រោះបើយើងវិភាគដើម្បីឱ្យមានការតាមដាន និងត្រួតពិនិត្យមើលថាតើអ្នកណានៅពីក្រោយខ្នង នៃការជំរុញមិនឱ្យទម្លាក់តម្លៃប្រេង ទៅតាមទីផ្សារអន្តរជាតិនេះ*" ។

លោក*សុន ឆ័យ* បានថ្លែងថា គណបក្សសម រង្ស៊ី សំដែងនូវការព្រួយបារម្ភ យ៉ាងខ្លាំងអំពីអនាគត បើសិនជារដ្ឋសភាខ្មែរ នៅតែបន្តធ្វើការងារតាមរបៀបប្រថាប់ត្រាឱ្យរដ្ឋាភិបាល ហើយបក្សនិងរដ្ឋគឺតែមួយដូចការគ្រប់គ្រងក្នុងទសវត្សរ៍១៩៨០នោះ, បើទោះបីជាតម្លៃប្រេងនៅលើទីផ្សារពិភពលោក ចុះមកនៅត្រឹម៤០ដុល្លារ នៅក្នុងមួយបារ៉ែល ក៏គ្មាននរណាអាចជួយប្រជាពលរដ្ឋបានដែរ ។

លោក*សុន ឆ័យ* បានបន្តថា ដោយសារតែមន្ត្រីជាន់ខ្ពស់ខ្មែរខ្លះ មានភាគហ៊ុនជាមួយក្រុមហ៊ុនប្រេងឥន្ធនៈនេះហើយទើបទីផ្សារប្រេង នៅកម្ពុជាតម្លៃថ្លៃខ្ពស់តាមចិត្តហើយមិនព្រមបញ្ចុះតម្លៃ ឱ្យស្របទៅតាមទីផ្សារអន្តរជាតិនោះ។

ដូច្នេះបញ្ហានាយករដ្ឋមន្ត្រីកាលពីថ្ងៃទី១៥ ខែកញ្ញាកន្លងទៅនេះ វាគ្រាន់តែជាការបិទបាំងចំណុចខ្សោយក្នុងការដឹកនាំរបស់ខ្លួនប៉ុណ្ណោះ៕

**តមកពីទំព័រ៤ ន**

ការសិក្សា នៅសាលាគរុកោសល្យក្បែរវិមានឯករាជ្យក្រុងភ្នំពេញនៅព្រឹកម្សិលមិញ ប្រមុខរដ្ឋាភិបាលកញ្ចប់ បានរំលឹកអំពីការគប់គ្រាប់បែក កាត់មុខក្បួនរថយន្ត អ្នកតំណាងរាស្ត្រអាណត្តិទី២ ចូលស្បថនៅខេត្តសៀមរាប កាលពីថ្ងៃទី២៤ខែកញ្ញា ១៩៩៨ ដែលលោក*ហ៊ុន សែន* ថាប៉ងសម្លាប់រូបគាត់ ។ ដូច្នេះ ការប្រជុំសភាអាណត្តិទី៤ នៅថ្ងៃទី២៤ កញ្ញា ២០០៨ នេះ គឺជារំលឹកខួប១០ឆ្នាំថាតើនឹងមានអ្វីកើតឡើងទៀត ។ ដូច្នេះសម្តីលោក*ហ៊ុន សែន* ទំនងជាគាត់ ចង់និយាយថា តើថ្ងៃទី២៤ កញ្ញា ប៉ុន្មានថ្ងៃខាងមុខនេះ មានគ្រាប់បេ-៤០ឆ្លងកាត់ក្បួនរថយន្តគាត់ ឬអ្នកតំណាងរាស្ត្រទៀតឬអត់ ?

លោក*ហ៊ុន សែន*ក៏បានថ្លែងអំពីកាសែត បាងកងប៉ុស្តិ៍របស់សៀម ដកស្រង់សម្តីរបស់គាត់ចុះផ្សាយខុសថា ជារឿងមិនធម្មតាទេ ។ ប៉ុន្តែសំរាប់ប្រជាពលរដ្ឋខ្មែរ និងអ្នកស្នេហាជាតិខ្មែរនិយាយថា ការចុះផ្សាយខុស របស់កាសែតសៀមនោះ អាចស្នើឱ្យគេកែតម្រូវបាន តែរឿងទាហានសៀម ឈ្លានពានទឹកដីខ្មែរ នៅតាមតំបន់ព្រំដែន ទើបជារឿងមិនធម្មតា ព្រោះទាហានឈ្លានពាន ទាំងនោះបានឈ្លានពាន បូរណភាពទឹកដីខ្មែរចំនួន៦៤ថ្ងៃហើយ គិតមកដល់ថ្ងៃនេះ គឺរយៈពេល២ខែនិង៣ថ្ងៃ។ ប៉ុន្តែអំពើឈ្លានពានរបស់សៀមនេះ បែរជាប្រមុខរដ្ឋាភិបាលកញ្ចប់ ត្រជាក់ល្ហឹម បានត្រឹមតែបញ្ជាឱ្យគ្រប់កងឯកភាពទាំងអស់ រក្សានូវភាពអត់ធ្មត់ ទោះបីជាពួកចោរសៀម បោះត្រាលើសាច់ខ្មែរពេលទៅទស្សនា ប្រាសាទតាមាន់ធំក៏បាន, សៀមបានឱ្យប្រជាពលរដ្ឋខ្មែរ អង្គុយលើកដៃ, ហើយឱ្យឆ្អែតហិត តាំងពីជើងដល់ក្បាលក៏បាន និងពួកចោរសៀម បាញ់ប្រជាពលរដ្ឋខ្មែរនៅតាមព្រំដែន ក៏បានដែរ ។ នេះទើបបានគេហៅថាជារឿងមិនធម្មតា ដែលលោកនាយករដ្ឋមន្ត្រី*ហ៊ុន សែន* ត្រូវនិយាយ និងមានវិធានការនោះ ។

លោក*ហ៊ុន សែន* បានលើកឡើងថាពួកប្រឆាំងសៀមបានប្រើប្រាស់ ប្រាសាទព្រះវិហារ ដើម្បីផ្តួលរំលំរដ្ឋាភិបាល លោក*សាម៉ាក់ ស៊ុនដារ៉ាវ៉េត* ។លោក*ហ៊ុន សែន*ក៏បាននិយាយដោយមិនលាក់លៀមដែរថា ទាហានសៀម បានឈ្លានពានចូលក្នុងដីខ្មែរនៅតំបន់ខ្លះក្បែរប្រាសាទព្រះវិហារយ៉ាងកំរោល ។ប៉ុន្តែលោក*ហ៊ុន សែន* និយាយថា ការដែលសៀម ឈ្លានពាននេះក៏ដោយសារតែ ភាគីកម្ពុជានិងសៀមប្រើផែនទីខុសគ្នា ។

ចំពោះភាគីកម្ពុជានិងសៀមប្រើប្រាស់ផែនទីខុសគ្នានេះទើបកម្ពុជាមិនហៅសៀមថា ឈ្លានពានកម្ពុជា ។ លោកនាយករដ្ឋមន្ត្រី*ហ៊ុន សែន* បាននិយាយយ៉ាងដូច្នេះថា"*...រដ្ឋាភិបាលថៃមានការលំបាក ដែលគេប្រើប្រាស់បញ្ហាចំណុចនយោបាយ, ប៉ុន្តែប្រាសាទព្រះវិហារ វត្តកែវសិក្ខាគីរីស្វារៈ អត់ត្រូវនិយាយអីជាមួយនរណាទេ...ចំពោះវត្តកែវសិក្ខាគីរីស្វារៈថៃប្រើប្រាស់ផែនទី ដែលគូសដោយឯកតោភាគី និងយើងប្រើប្រាស់ដោយផែនទីមួយ ដែលជាផែនទីឧបសម្ព័ន្ធ នៃតុលាការអន្តរជាតិក្រុងឡាអេ ។ ដល់ចំណុចនេះហើយ បានជាកម្ពុជា មិនប្រើប្រាស់ពាក្យឈ្លានពាន ដោយសារមូលហេតុ ផ្តើមចេញពីការដែលប្រើប្រាស់ផែនទី មិនឯកភាពគ្នា...*" ។

អ្នកស្តាប់សម្តី លោកនាយករដ្ឋមន្ត្រី*ហ៊ុន សែន* កន្លែងនេះផ្ទុយពីឃ្លាខាងលើ គឺមានន័យថា ពួកទាហានឈុតខ្មៅសៀមអត់ឈ្លានពានទឹកដីខ្មែរទេ នៅពេលដែល ស្ថានីយ៍ និងវិទ្យុទូរទស្សន៍ ពិសេសសារព័ត៌មានគាំទ្រគណបក្សប្រជាជន បានចោទប្រកាន់ថា ទាហានឈុតខ្មៅសៀមឈ្លានពានខ្មែរនោះ។

លោក*ហ៊ុន សែន* ក៏ដូចជាមន្ត្រីរដ្ឋាភិបាលខ្មែរបានទៅចរចា ជាមួយភាគីចោរសៀមនៅពេលមុនដែរ គឺចង់អោយស្ថានការណ៍នៅតាមព្រំដែនមានដូចមុនថ្ងៃទី១៥ កក្កដា២០០៨ ។

ការនិយាយ ត្រឡប់ត្រឡិនរបស់លោក*ហ៊ុន សែន* កាលពីព្រឹកម្សិលមិញនោះ សង្ឃឹមថាការជ្រើសរើស នាយករដ្ឋមន្ត្រីបានជោគជ័យ បន្តការចរចាទៀត ដើម្បីបញ្ចប់ការរំលោភយ៉ាងអនាធិបតេយ្យដោយកងទ័ពសៀម នៅតាមតំបន់នានាទៀតដូចជាជប់គគីរជាដើម ។

ដូច្នេះសម្តី នាយករដ្ឋមន្ត្រីកញ្ចប់*ហ៊ុន សែន* កាលពីព្រឹកម្សិលមិញនោះ វាត្រឡប់ត្រឡិនបាយបិណ្ឌជាបាយបាត្រ គឺម្តងថាសៀមបានឈ្លានពានខ្មែរយ៉ាងកំរោល និងម្តងថាភាគីកម្ពុជា មិនទាន់ថាសៀមឈ្លានពានខ្មែរទេ ។ ជាមួយគ្នានោះលោក*ហ៊ុន សែន* ស្នើនាយករដ្ឋមន្ត្រីទើបជាប់ឆ្នោតថ្មី របស់សៀម បញ្ជូនគណៈប្រតិភូសៀមបន្តការចរចាជាមួយខ្មែរទៀត ។

ទោះយ៉ាងណា លោក*ហ៊ុន សែន*មិនបានអះអាងអំពីវិធានការអ្វីក្រៅតែពីសុំចរចាជាមួយចោរនោះទេ ដែលនេះបានធ្វើឱ្យចោរសៀម កាន់តែបានចិត្ត ហើយបន្តលុកលុយ នៅកន្លែងផ្សេងៗទៀត ដូចជាកាលពីថ្ងៃទី១៥ កញ្ញា ២០០៨ ទាហានឈុតខ្មៅសៀម ចំនួន៣០នាក់បានចូលមករុះរើលំនៅឋានប្រជាពលរដ្ឋខ្មែរចំនួន៣ នៅក្បែរប៉ុស្តិ៍ព្រំដែនជាំស្រងាំ ប្រមាណតែ៧០ម៉ែត្រប៉ុណ្ណោះ៕

**សេវាទទួលទិញសម្ភារៈចាស់ៗ**

មានទទួលទិញ : ផ្ទះឈើ ផ្ទះថ្ម និងសំណង់អគារចាស់ៗតូច-ធំ គ្រប់ប្រភេទដែលត្រូវការរុះរើ ឬវាយចោល និង សម្ភារៈអេតចាយជាច្រើនមុខទៀតដូចជា : ដែក ស្ពាន់ អាលុយមីញ៉ូម ម៉ាស៊ីនត្រជាក់ ម៉ាស៊ីនភ្លើង អាគុយ ម៉ូទ័រ ។ល។

-មានសេវាចុះទិញតាមខេត្ត-ក្រុងទូទាំងប្រទេសកម្ពុជា
-មានទទួលទិញក្នុងតម្លៃសមរម្យ
-ចំពោះអ្នកដែលផ្តល់ព័ត៌មានក្នុងការទិញលក់នេះ ក្រុមហ៊ុននឹងផ្តល់កម្រៃជើងសារបន្ថែម

ទំនាក់ទំនងទូរស័ព្ទលេខ : **017 606 125**

**ដំណឹងល្អ!**

ផ្សព្វផ្សាយពាណិជ្ជកម្មលើទំព័រសារព័ត៌មាន ខ្មែរម្ចាស់ស្រុក នឹងទៅដល់គ្រប់ទីកន្លែងក្នុងប្រទេសកម្ពុជា
សូមទាក់ទងមកកាន់ ០១២ ៨៥០ ៦៩០ / ០១៥ ៦៤៥ ១៧០

**ក្រុមហ៊ុនភាពយន្ត ជនបទ**

**មានទទួលបញ្ចាំង ខ្សែភាពយន្តខ្នាតធំ ក្នុងពិធីផ្សេងៗ មានពន្លឺច្បាស់ ទំនាក់ទំនងតាមទូរស័ព្ទ**
**012 66 44 67**
**015 66 44 67**

Khmer Machas Srok News
ការិយាល័យនិពន្ធ
Tel : 012 969 832 , 012 850 690
Fax : 023 987 411
E-mail: kmsnews@gmail.com
www.kmsblog.wordpress.com
ផ្នែកផ្សាយពាណិជ្ជកម្ម
Tel: 012 850 690 , 017 360 678,
015 645 170

**សារព័ត៌មាន "ខ្មែរម្ចាស់ស្រុក" ប្រចាំថ្ងៃ ទំព័រទី០៤**
Tel: 012 850 690 / 017 360 678 , Fax: 023 987 411

**តមកពីទំព័រ១ ម**

ពិភពលោក។

នៅវេលារសៀលនៃថ្ងៃអង្គារ អគ្គលេខាធិការរងនៃក្រសួងការបរទេសសៀម *ថានី ថុង ផាទី* បាននិយាយចោទប្រកាន់ថា ទាហានខ្មែរប្រមាណ៣០ នាក់បានរំលោភចូលទឹកដីថៃនៅត្រង់តំបន់ប្រាសាទតាក្របី។ នេះគឺជាសេចក្តីថ្លែងមួយដែលធ្វើឱ្យមានការភ្ញាក់ផ្អើលជាទូទៅ។

ហើយអ្វីដែលគេអាចយល់បានពីការប្រកាសនៃមន្ត្រីជាន់ខ្ពស់ក្រសួងការបរទេសសៀមនេះគឺថា ការលើកទាហានសៀមប្រដាប់អាវុធឈុតខ្មៅគាំទ្រដោយទាហានសៀមប៉ារ៉ាចូលកាន់កាប់វត្តកែវសិក្ខាគិរីស្វារៈ ឬវត្តប្រាសាទព្រះវិហារនៅលើតំបន់ប្រាសាទព្រះវិហារដែលតុលាការអន្តរជាតិក្រុងឡាអេសម្រេចថាជាទឹកដីរបស់ខ្មែរក្នុងឆ្នាំ១៩៦២ និងសៀមបានបន្តលើកទាហានចូលរាតត្បាតកាន់កាប់ដីខ្មែរច្រើនកន្លែងទៀតតាមបណ្តោយព្រំដែននោះ គឺច្បាស់ណាស់ថា ជាចេតនាឈ្លានពានរបស់សៀមសុទ្ធសាធ។

បន្ទាប់ពីនោះទាហានសៀមប្រដាប់អាវុធបានចូលលុកលុយកាន់កាប់ប្រាសាទតាមាន់ធំ លើទឹកដីខ្មែរស្រុកបន្ទាយអំពិល ខេត្តឧត្តរមានជ័យហើយសៀមបានបន្តកាន់កាប់ដីខ្មែរច្រើនកន្លែងទៀត រហូតដល់ប្រាសាទតាក្របីចំងាយប្រមាណ១៥គីឡូម៉ែត្រពីគ្នានោះ ទាំងអស់ហ្នឹងសុទ្ធសឹងតែជាផែនការ នៃការឈ្លានពានរបស់ទាហានសៀមប្រើលេសភាពវឹកវរនយោបាយនៅក្នុងប្រទេសរបស់ខ្លួន។

ស្ថានការណ៍នៃការប្រឈមមុខផ្នែកយោធាប្រដាប់អាវុធរវាងកងទ័ពខ្មែរ និងកងទ័ពសៀមឈ្លានពាននៅតំបន់ប្រាសាទព្រះវិហារដែលគេគិតថាមានសភាពស្ងប់មួយរយៈពេលនោះ នៅពេលនេះក៏ចាប់កំរើកឡើង បណ្តាលឱ្យមានការភ្ញាក់ផ្អើល។ តាមរបាយការណ៍ពីប្រភពនានាថា ទាហានសៀមបានរៀបក្បួនទ័ពដែលមានកម្លាំងគាំទ្រពីក្រោយនៅតាមផ្លូវជាតិ និងតំបន់ប្រាសាទព្រះវិហារនៃទឹកដីខ្មែររបៀបជាការរៀបកម្លាំងបណ្តាក់កងទ័ពសម្រាប់ប្រុងជើងការអ្វីមួយ។

នៅវេលាយប់ថ្ងៃទី១៤ ខែកញ្ញាតាមព័ត៌មានថាកងទាហានសៀមបានជ្រៀតលួចចូលពេលយប់សំដៅដល់ជណ្តើរប្រាសាទបុរាណនៃប្រាសាទព្រះវិហារ។

នៅឯច្រកតាថាវឯណោះវិញពេលដែលទាហានខ្មែរឈរជើងនៅទីនោះបង្ហាញនូវភាពស្ងប់ជាធម្មតា នៅថ្ងៃទី១១ ខែកញ្ញា បែរជាទាហានសៀមប្រមាណជា១០នាក់លួចចូលមកក្នុងច្រកតាថាវក្នុងទឹកដីខ្មែរ។ នេះនៅមិនគិតអំពីការជ្រៀតចូលរបស់ទាហានប្រដាប់អាវុធសៀមឈ្លានពាននៅតំបន់ផ្សេងៗនៃទឹកដីខ្មែរដែលពុំមានកងទាហានខ្មែរឈរជើងប្រចាំការនោះផងទេ។

យ៉ាងណាក៏ដោយសកម្មភាពរំលោភបំពានរបស់ទាហានសៀមយ៉ាងគឃ្លើន ក៏តែងតែបានប្រញាប់ដកថយចេញពីទឹកដីខ្មែរនៅពេលបានឃើញទាហានខ្មែរដើរល្បាត។

អំពីទឹកដីតំបន់ប្រាសាទតាក្របីជាប្រាសាទនៃស្នាដៃបុព្វបុរសខ្មែរ ហើយដែលមន្ត្រីជាន់ខ្ពស់ការបរទេសសៀមបានប្រកាសថា គឺជាទឹកដីសៀមនោះ ក៏មានឧប្បត្តិហេតុវិវត្តន៍នៃការរំលោភឈ្លានពានរបស់ទាហានសៀមជាហូរហែដែរ។

នៅថ្ងៃទី១០ កញ្ញា ទាហានឈុតខ្មៅសៀមប្រមាណ១២ នាក់បានរំលោភបំពានឆ្លងដែនចូលមកកាន់កាប់ប្រាសាទតាក្របី។ ហើយមួយថ្ងៃបន្ទាប់នោះ ចំនួនទាហានសៀមបញ្ជូនចូលមកបានកើនឡើងដល់៤០ នាក់ ថ្វីបើពីរថ្ងៃក្រោយមកទៀតពួកទាហានសៀមបានយល់ព្រមដកថយពីប្រាសាទតាក្របីទៅឈរជើងនៅចំងាយប្រមាណ៣០០ម៉ែត្រពីតួប្រាសាទ។

ការប្រកាសរបស់មន្ត្រីជាន់ខ្ពស់ក្រសួងការបរទេសរដ្ឋាភិបាលសៀមក្រុងបាងកកថាទាហានខ្មែរជាអ្នកចូលឈ្លានពានប្រាសាទតាក្របីដែលសៀមអះអាងថាទឹកដីរបស់ខ្លួននោះក៏ឆ្លុះបញ្ចាំងឱ្យឃើញយ៉ាងច្បាស់ថារដ្ឋាភិបាលសៀមពិតជាមានផែនការនិងចេតនាច្បាស់លាស់ក្នុងការបញ្ជូនទាហានឱ្យចូលរំលោភបំពានកាន់កាប់ដីខ្មែរតាមបណ្តោយខ្សែព្រំដែនរវាងប្រទេសទាំងពីរ ដែលសៀមខ្លួនឯងបានទទួលស្គាល់ជាអន្តរជាតិតាំងពីជិតកន្លះសតវត្សរ៍មុនជាហូរហែមកនោះ។

ភ្ជាប់ជាមួយការប្រកាសរបស់មន្ត្រីក្រសួងការបរទេសសៀមនេះ គេអាចយល់បានថាការចរចាទ្វេភាគីជាការសុំរបស់ទាហានសៀមឱ្យកម្ពុជាកុំបន្តប្តឹងទៅក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ និងវេទិការអន្តរជាតិនានា គឺជាល្បិចនយោបាយរបស់សៀមសុទ្ធសាធ។ ពោលគឺសៀមប្រើវិធីព្យាយាមបំភ័ន្តសាធារណៈមតិពិភពលោកដោយបោកប្រទេសកម្ពុជាឱ្យចូលចរចាតែពីរភាគីខ្មែរ និងសៀម ដើម្បីអ្វីដែលសៀមពន្យល់បំភ័ន្តពិភពលោកថារកដំណោះស្រាយតាមសន្តិវិធីបញ្ចប់បញ្ហាជម្លោះរវាងប្រទេសទាំងពីរតាមតំបន់ព្រំដែន។

ប៉ុន្តែច្បាស់បំផុតនោះ បានឆ្លុះបញ្ចាំងឱ្យឃើញថា សៀមគ្មានចេតនានឹងរកដំណោះស្រាយដោយសន្តិវិធី តាមកិច្ចពិភាក្សាទ្វេភាគីរវាងខ្មែរនិងសៀមដើម្បីបញ្ចប់បញ្ហានៃការប្រឈមមុខដាក់គ្នា រវាងកងទាហាននៃប្រទេសទាំងពីរនៅតាមខ្សែបន្ទាត់ព្រំដែននោះឡើយ។

ព្រោះថា គឺសៀមខ្លួនឯងជាអ្នកបានបង្កហេតុដោយបញ្ជូនទាហានរបស់ខ្លួនឱ្យចូលកាន់កាប់ទឹកដីខ្មែរ ទាំងខ្លួនឯងបានដឹងយ៉ាងច្បាស់ថា សាលក្រមតុលាការអន្តរជាតិក្រុងឡាអេសម្រេចអំពីទឹកដីតំបន់ខ្សែបន្ទាត់ព្រំដែនរវាងទឹកដីប្រទេសទាំងពីរ។

សាលក្រមតុលាការយុត្តិធម៌អន្តរជាតិក្រុងឡាអេថ្ងៃ១៥ មិថុនា ឆ្នាំ១៩៦២ សម្រេចដោយផ្អែកលើអនុសញ្ញាបារាំងសៀមឆ្នាំ១៩០៤ និងសន្ធិសញ្ញាបារាំង-សៀមឆ្នាំ១៩០៧ ដែលប្រទេសទាំងពីរចុះហត្ថលេខានឹងគ្នាស្តីអំពីការកំណត់ខ្សែបន្ទាត់ព្រំដែនរវាងប្រទេសខ្មែរ និងសៀមដែលមានការទទួលស្គាល់ជាអន្តរជាតិ។ហើយតុលាការអន្តរជាតិក្រុងឡាអេបានប្រើប្រាស់ឯកសារទាំងនោះដើម្បីចេញសាលក្រមសម្រេច ទាំងសៀមខ្លួនឯងក៏បានទទួលស្គាល់រយៈពេលជាង៤៦ឆ្នាំមកនេះផង។

ដូច្នេះការដែលទាហានសៀមបានលើកគ្នាចូលកាន់កាប់តំបន់ទឹកដីខ្មែរក្បែរព្រំដែនរវាងប្រទេសខ្មែរ និងសៀម គឺពិតជាផ្នែកមួយនៃផែនការនយោបាយ និងចេតនារំលោភឈ្លានពានចង់បានទឹកដីខ្មែរដោយភាពគឃ្លើន ព្រហើន ថ្វីបើនៅពេលនេះសៀមមានហេតុផលលេសអាចបិទបាំងថា ភាពចលាចលវឹកវរនយោបាយប្រទេសសៀមធ្វើឱ្យមានដំណើរយឺតយូរ និងរាំងស្ទះដល់ដំណើរការចរចាថ្នាក់រដ្ឋមន្ត្រីការបរទេស នៃប្រទេសទាំងពីរនោះ។

ចាប់តាំងពីរសៀលថ្ងៃអង្គារទី១៦ ខែកញ្ញាមក ទើបនាយករដ្ឋមន្ត្រីកម្ពុជា *ហ៊ុន សែន* ភ្លឺភ្នែកដឹងច្បាស់ថា ជាហូរហែកន្លងមកសៀមបានបោកប្រាស់កម្ពុជា។ គឺជាការដឹងខ្លួនដែលយឺតពេល ថ្វីបើមិនហួសពេលហើយដែលនៅសល់តែផ្លូវមួយគត់សម្រាប់ប្រទេសកម្ពុជា ក្នុងការរកដំណោះស្រាយបញ្ចៀសការប្រឈមមុខដាក់គ្នាដើម្បីបញ្ចប់បញ្ហាជម្លោះព្រំដែនជាមួយប្រទេសសៀមនោះ គឺរដ្ឋាភិបាលគណបក្សប្រជាជន *ហ៊ុន សែន*ត្រូវតែទទួលស្គាល់នូវការពិតដូចមតិរបស់គ្រប់មជ្ឈដ្ឋាននិងអ្នកសង្កេតការណ៍អន្តរជាតិមួយចំនួនថា កម្ពុជាមានតែផ្លូវយកបញ្ហានេះទៅប្តឹងដល់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ ឬតុលាការអន្តរជាតិតែប៉ុណ្ណោះ។

ហើយតាមមើលការពិនិត្យហេតុការណ៍វិវត្តន៍ជាក់ស្តែងនៃបញ្ហាផ្នែកយោធារវាងខ្មែរនិងសៀមតាមបណ្តោយព្រំដែនចាប់តាំងពីសៀមបានលើកគ្នាជាទាហានឈុតខ្មៅប្រដាប់អាវុធការពារ គាំទ្រដោយទាហានប៉ារ៉ាចូលកាន់កាប់វត្តកែវសិក្ខាគិរីស្វារៈឬវត្តប្រាសាទព្រះវិហារនៅតំបន់ប្រាសាទព្រះវិហាររបស់ខ្មែរនៅថ្ងៃទី១៥ ខែកក្កដាឆ្នាំ២០០៨ជាហូរហែមកសៀមបានពង្រីកបញ្ហាដោយដាក់ទាហានរបស់ខ្លួនចូលឈ្លានពានកាន់កាប់ទឹកដីខ្មែរតំបន់ផ្សេងៗទៀតតាមខ្សែបន្ទាត់ព្រំដែន។

ទាហានខ្មែរនៅតំបន់ប្រាសាទតាមាន់ធំរបស់កម្ពុជាក៏កំពុងប្រឈមនឹងទាហានសៀមហើយពួកទាហានសៀមក៏នៅបានលើកគ្នាចូលកាន់កាប់ទឹកដីខ្មែរនៅច្រកជាំសាងុាំផងដែរ មិនមែនត្រឹមតែតំបន់ផ្សេងៗជាច្រើនបន្តបន្ទាប់មក តាំងតែពីទាហានសៀមបានលើកគ្នាចូលកាន់កាប់តំបន់ទឹកដីប្រាសាទព្រះវិហារកណ្តាលខែកក្កដារៀងមកនោះ។

មជ្ឈដ្ឋាននានាបានវាយតម្លៃថា ការប្រកាសរបស់នាយករដ្ឋមន្ត្រី *ហ៊ុន សែន* នៃរដ្ឋាភិបាលកម្ពុជាថា កម្ពុជាឈប់អត់ធ្មត់តទៅទៀតរឿងទាហានសៀមចេះតែបន្តការឈ្លានពានតាមតំបន់ព្រំដែនខ្មែរនោះការប្រកាសបែបនេះគឺជាជម្រើសផ្លូវត្រូវដែលមានការអបអរជាទូទៅ។

ប៉ុន្តែយ៉ាងណាក៏ដោយ ក៏មានការរំលឹកផងដែរថាមេដឹកនាំកម្ពុជា ជាពិសេស *ហ៊ុន សែន* មិនត្រូវចេះតែស្តាប់តាមការល្បួងរបស់មេដឹកនាំសៀមដោយលើកហេតុផលអំពីផលប្រយោជន៍សេដ្ឋកិច្ចក្នុងទឹកប្រាក់វិនិយោគទុនរាប់រយលានដុល្លាររវាងប្រទេសជិតខាងទាំងពីរដើម្បីបិទបាំងភាពគឃ្លើនចំពោះមុខនយោបាយការទូតរបស់សៀមនោះទេ៕

**តមកពីទំព័រ១ ន**

សៀមរំលោភមកលើអធិបតេយ្យភាព និងបូរណភាពទឹកដីខ្មែរ។

លិខិតលោក*សម រង្ស៊ី*ដែលបានធ្វើឡើងកាលពីថ្ងៃទី១៧ ខែកញ្ញា ម្សិលមិញនេះ មានខ្លឹមសារជាអាទិ៍ថា "*ជាការចាំបាច់ណាស់ដែលតម្រូវឱ្យរដ្ឋាភិបាលស្នើសុំការឧបត្ថម្ភពីសហប្រធាននៃសន្និសីទទីក្រុងប៉ារីសស្តីពីកម្ពុជា ថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ ដែលមានប្រទេសឥណ្ឌូណេស៊ី និងសាធារណរដ្ឋបារាំងឱ្យជួយខ្មែរក្នុងករណីដែលអធិបតេយ្យភាពនិងបូរណភាពទឹកដីខ្មែរត្រូវបានរំលោភ និងគំរាមកំហែងដោយកងទ័ពថៃបច្ចុប្បន្ននេះ*"។

លិខិតលោក *សម រង្ស៊ី* បានបន្តទៀតថា "*មាត្រា៥ ក្នុងផ្នែកទាក់ទងនឹងអធិបតេយ្យភាព ឯករាជ្យ បូរណភាព និងភាពមិនអាចរំលោភបាននៃដែនដី អព្យាក្រឹត និងឯកភាពជាតិកម្ពុជានៃកិច្ចព្រមព្រៀងទីក្រុងប៉ារីសនេះបានចែងយ៉ាងច្បាស់ដែលរដ្ឋាភិបាលខ្មែរអាចស្នើសហប្រធាននេះឱ្យកោះប្រជុំប្រទេសទាំងឡាយជាហត្ថលេខីដែលមានប្រទេសថៃផងដែរធានាឱ្យបាននូវបូរណភាពទឹកដីខ្មែរ តាមរយៈកិច្ចព្រមព្រៀងដែលរៀបចំដោយអង្គការសហប្រជាជាតិនេះ*"។

លិខិតលោក *សម រង្ស៊ី* បានបញ្ជាក់ជូនលោក *ហ៊ុន សែន* យ៉ាងច្បាស់ថា "*បើមានការស្នើទៅសហប្រធាន នៃសន្និសីទទីក្រុងប៉ារីសនោះនឹងធ្វើឱ្យមានការគាំទ្រយ៉ាងពេញទំហឹងពីពលរដ្ឋគ្រប់និន្នាការនយោបាយរួមទាំងសង្គមស៊ីវិលហើយបញ្ញវ័ន្តខ្មែរទាំងអស់នឹងស្ម័គ្រចិត្តចូលរួមព្រោះជាមធ្យោបាយក្នុងកិច្ចការពារបូរណភាពទឹកដី របស់យើងឱ្យទទួលបានជោគជ័យទាំងស្រុងជាពុំខានឡើយ*"។

គំនិតដ៏ល្អរបស់លោក *សម រង្ស៊ី* នេះមិនដឹងថា លោក *ហ៊ុន សែន* ទទួលបាន ឬមិនបាននោះទេ ព្រោះ នាយករដ្ឋមន្ត្រីកញ្ចប់ជិតចប់អាណត្តិ និងគ្រោងទទួលតំណែងជានាយករដ្ឋមន្ត្រីកញ្ចប់នៅប៉ុន្មានថ្ងៃខាងមុខនេះ បានបន្តវាយប្រហាររិះគន់លោក*សម រង្ស៊ី*ប្រធានគណបក្សប្រឆាំង ដែលបាននិយាយភាពចន្លោះប្រហោង នៃការដឹកនាំរបស់គាត់ នាពេលកន្លងមក ។ សម្តីលោក*ហ៊ុន សែន* ដែលហាក់ដូចជា យកលោក *សម រង្ស៊ី* ជាខ្មែរធ្វើជាសត្រូវ, ហើយធ្វើអន់ ជាមួយពួកចោរសៀមឈ្លានពាននេះ បានធ្វើឱ្យប្រជាពលរដ្ឋ ហួសចិត្តយ៉ាងខ្លាំង ។ តែការវាយប្រហារនោះ លោក*ហ៊ុន សែន* មិនហ៊ាននិយាយចំឈ្មោះ លោក *សម រង្ស៊ី* ឡើយ ។

ថ្លែងនៅក្នុងពិធី ចែកសញ្ញាប័ត្រ ដល់និស្សិតទើបតែបញ្ចប់

**តទៅទំព័រ៣ ន**

**តមកពីទំព័រ១ ក**

**ហើយនេះគឺជាបន្ទុកបញ្ហាបន្ថែមលើទម្រង់ នៃបញ្ហាដែលប្រទេសកម្ពុជាទាំងមូល និងប្រជារាស្ត្រខ្មែរទូទាំងប្រទេសកំពុងប្រឈម។**

**នោះគឺបញ្ហានៃការរំលោភសិទ្ធិមនុស្សដែលមាននៅគ្រប់ទិសទី ជាក់ស្តែងដូចជាការរំលោភប្លន់យកដីធ្លីស្រែចំការផ្ទះសម្បែងរបស់ប្រជារាស្ត្រខ្មែរពីសំណាក់ពួកអ្នកមានតំណែងអំណាចធំជាមន្ត្រីសែគណបក្សប្រជាជន ហ៊ុន សែន ក៏ដូចជាពួកឈ្មួញឱកាសនិយមជាបក្ខពួករបស់ពួកគេ។ ហើយនេះ ក៏មិនមែនជាបញ្ហាដោយឡែកនោះដែរ ប៉ុន្តែក៏គឺជាទម្ងន់បញ្ហាដាក់សង្កត់លើជីវភាពរបស់ប្រជារាស្ត្រខ្មែរបន្ថែមពីការដឹកនាំដ៏មហាពុករលួយរបស់រដ្ឋាភិបាលគណបក្សប្រជាជនហ៊ុនសែនបង្កើតអយុត្តិធម៌ពាសពេញប្រទេសឱ្យប្រជារាស្ត្រខ្មែររងគ្រោះ។**

**មើលចុះ ជាក់ស្តែងប៉ុន្មានថ្ងៃមុននេះ ហ៊ុន សែន ខ្លួនឯងក៏បានថ្លែងក្តែងៗដូចដែលដឹងខ្លួនអំពីទំហឹករាលដាលនៃប្រតិកម្មរបស់ប្រជារាស្ត្រខ្មែររងគ្រោះនិងឈឺចាប់ពីការដឹកនាំប្រទេសរបស់គណបក្សប្រជាជន ហ៊ុន សែន ឱ្យទំនិញឡើងថ្លៃសព្វសារពើ។ គឺ ហ៊ុន សែន បានធ្វើជានឹកនិយាយអំពីបញ្ហាប្រេងសាំងឡើងថ្លៃមិនព្រមចុះតាមតម្លៃនៅទីផ្សារពិភពលោកដែលបានចុះថ្លៃហើយនោះ។ គឺជាការនិយាយរបៀបដឹងខ្លួន ហើយខំដោះសាកុំឱ្យមានការស្តីបន្ទោស ជាពិសេសកុំឱ្យមានការថ្កោលទោសពីប្រជារាស្ត្ររងគ្រោះចំពោះនយោបាយដឹកនាំគ្មានប្រសិទ្ធភាពរបស់រដ្ឋាភិបាលខ្លួននោះ។**

**ហ៊ុន សែន បាននិយាយថា តម្លៃប្រេងនៅលើទីផ្សារអន្តរជាតិបានចុះដល់ទៅ២៥ភាគរយទៅហើយ ប៉ុន្តែប្រេងនៅប្រទេសខ្មែរបែរជាចុះត្រឹមតែ១០ភាគរយ។ ការនិយាយបែបនេះរបស់ ហ៊ុន សែន គឺគ្រាន់តែជាការព្យាយាមលុបលាងកំហុសខ្លួនតែប៉ុណ្ណោះ ពីព្រោះដូចអង្គការបរទេសមួយទើបផ្សាយថ្មីៗនេះថា ប្រពន្ធរបស់ ហ៊ុន សែន កូនស្រីរបស់ ហ៊ុន សែន និងមនុស្សគណបក្សប្រជាជនជាច្រើននាក់ទៀតសុទ្ធតែមានចំណែកភាគហ៊ុនក្នុងក្រុមហ៊ុននាំប្រេងចូលធំៗ។**

**ដូច្នេះពុំមានអ្វីប្លែកនោះទេ ការដែល ហ៊ុន សែន បានធ្វើជាចេញស្រែកអំពីបញ្ហាប្រេងឡើងថ្លៃ ក៏ព្រោះតែគាត់ដឹងថា ប្រពន្ធកូនគាត់មានចំណែកភាគហ៊ុនក្នុងក្រុមហ៊ុនប្រេងដែលកេងប្រវ័ញ្ចលើញើសឈាមរបស់ប្រជាពលរដ្ឋខ្មែរ ដូច្នេះពេលមានប្រតិកម្មពីប្រជារាស្ត្រ ក៏នឹងមានការថ្កោលទោសដល់ក្រុមគ្រួសាររបស់គាត់ដែលដឹងតែប្រមូលកើបលុយមិនខ្វល់ថា ប្រជារាស្ត្រខ្មែររងគ្រោះដោយសារបញ្ហាទំនិញឡើងថ្លៃ និងប្រេងឡើងថ្លៃនោះទេ។**

**របៀបរបបគ្រប់គ្រងប្រទេសរបស់ ហ៊ុន សែន និងគណបក្សប្រជាជននេះ បើនៅតាមប្រទេសនានាដូចជានៅប្រទេសសៀមក្បែរកម្ពុជា ច្បាស់ណាស់ថា ហ៊ុន សែន និងរដ្ឋាភិបាលគណបក្សប្រជាជនមុខតែដួលរលំក្នុងពេលដ៏ខ្លីមិនលែងឡើយ។ នៅប្រទេសសៀមជាក់ស្តែងនោះ នាយករដ្ឋមន្ត្រីសៀម សាម៉ាក់ ស៊ុនដារ៉ាវេត ថ្វីបើគណបក្សរបស់គាត់បានឈ្នះឆ្នោតនាំមុខគេ និងផ្តល់ឱកាសដល់គាត់បានធ្វើជានាយករដ្ឋមន្ត្រី ក៏ទីបំផុតមហាបាតុកម្មរបស់មហាជនបានទម្លាក់សាម៉ាក់ ចេញពីតំណែងជាមេដឹកនាំរដ្ឋាភិបាលសៀម ដោយសាម៉ាក់ ខ្លួនឯងមិនអស់ចិត្តសោះឡើយ។ យ៉ាងណាក៏ដោយនេះជាមេរៀនបង្ហាញថា ប្រទេសគេ គេគិតគូរដល់វាសនាសង្គមទាំងមូល និងដើម្បីកុំឱ្យប្រទេសគេបែកបាក់នាយករដ្ឋមន្ត្រី សូម្បីតែជាប់ឆ្នោតត្រឹមត្រូវ ក៏ត្រូវបង្ខំចិត្តលាលែងពីមុខតំណែង ហើយមិនមែនដូចនៅកម្ពុជាដែល ហ៊ុន សែន គណបក្សប្រជាជនប្រើប្រាស់កម្លាំងប្រដាប់អាវុធអាចបង្ក្រាបប្រជារាស្ត្រក្នុងបំណងរក្សាអំណាចរបស់ខ្លួន ដោយមិនខ្វល់ដល់ដំណើរការរបស់ប្រទេសជាតិស្ថិតក្នុងគ្រោះថ្នាក់នោះទេ។**

**ហេតុការណ៍នោះ ក៏ដូចជាការរង់ចាំរយៈពេលមួយសប្តាហ៍ទៀត ក៏កំពុងធ្វើឱ្យ ហ៊ុន សែន នឹកស្រមៃទាំងភ័យអរថា មិនដឹងជាការបោះឆ្នោតកញ្ចប់នឹងធានាឱ្យខ្លួនបានធ្វើជានាយករដ្ឋមន្ត្រី ឬមួយក៏មានហេតុការណ៍ផ្សេងយ៉ាងណាទើបបានជា ហ៊ុន សែន បង្ខំឱ្យគណបក្សប្រជាជនខ្លួនឯងត្រូវតែធានានូវការបោះឆ្នោតជាកញ្ចប់តែងតាំងខ្លួនឱ្យធ្វើជានាយករដ្ឋមន្ត្រី តំណាលគ្នានឹងការជ្រើសតាំងប្រធាន និងអនុប្រធាននៃសភាជាតិថ្មី ទោះបីរដ្ឋធម្មនុញ្ញនិយាយក្នុងសេចក្តីចែងផ្ទុយពីនេះក៏ដោយចុះ៕**